ថ្មីៗនេះ មានការណែនាំពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឱ្យផ្អាកការរៀបចំការប្រលងពលករជំនាញកម្រិត1ក្នុងវិស័យភោជនីយដ្ឋានទាំងនៅក្នុងនិងក្រៅប្រទេស ដូច្នេះហើយនីតិវិធីនៃការចុះឈ្មោះប្រលងនេះ នឹងត្រូវផ្អាករហូតដល់មានការណែនាំឱ្យចាប់ផ្តើមឡើងវិញ។

គួរបញ្ជាក់ដែរថា ចំពោះការប្រលងពលករជំនាញកម្រិត2ក្នុងវិស័យភោជនីយដ្ឋាន និងការប្រលងពលករជំនាញកម្រិត1និងកម្រិត 2ក្នុងវិស័យផលិតចំណីអាហារ និងភេសជ្ជៈ គឺនៅតែទទួលតាមនីតិវិធីចាំបាច់នៃការកក់ការប្រលងដូចដែលបានគ្រោងទុក។

ការណែនាំឱ្យផ្អាកការប្រលងនេះ គឺដោយសារតែចំនួនអ្នកមានសិទ្ធិស្នាក់នៅជាពលករជំនាញកម្រិត1ក្នុងផ្នែកភោជនីយដ្ឋាន ត្រូវបានគេរំពឹងថានឹងលើសពីចំនួនកំណត់អតិបរមា(5ម៉ឺននាក់) សម្រាប់រយៈពេល5ឆ្នាំ(ចាប់ពីឆ្នាំសារពើពន្ធ2024 ដល់ 2028)ដែលបានកំណត់ដោយរដ្ឋាភិបាលជប៉ុន ※ អាស្រ័យហេតុនេះ ការប្រលងក៏ត្រូវបានសម្រេចឱ្យផ្អាកផងដែរ។ចំពោះពេលវេលាជាក់លាក់នៃការចាប់ផ្តើមការប្រលងឡើងវិញនោះ គឺមិនទាន់មានការបញ្ជាក់ឱ្យដឹងពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅឡើយទេ។

※ចំពោះព័ត៌មានលម្អិត សូមចូលទៅពិនិត្យមើលគេហទំព័ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងគេហទំព័រភ្នាក់ងារអន្តោប្រវេសន៍។

សេចក្តីប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់

និងនេសាទស្តីអំពីការទទួលយកជនជាតិមនុស្សបរទេសក្នុងវិស័យភោជនីយដ្ឋាន :

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

សេចក្តីប្រកាសរបស់ភ្នាក់ងារអន្តោប្រវេសន៍ស្តីអំពីការអនុវត្តចំនួនកំណត់អតិបរមានៃការទទួលយកពលករជំនាញ "វិស័យភោជនីយដ្ឋាន" ភ្នាក់ងារអន្តោប្រវេសន៍

រាល់ការសាកសួរព័ត៌មានពាក់ព័ន្ធនឹងគោលការណ៍ផ្អាកការប្រលងនេះ

សូមប្រើប្រាស់ទម្រង់បែបបទសាកសួរព័ត៌មានរបស់ផ្នែកភោជនីយដ្ឋាន និងវប្បធម៌អាហារនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ (តំណភ្ជាប់) [ទម្រង់បែបបទសាកសួរព័ត៌មាន]របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ